EAC

# អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA

# ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
ELECTRICITY LAW OF THE KINGDOM OF CAMBODIA

## សេចក្តីសម្រេចកែសម្រួលលើកទី៧
## លើឯកសារអាជ្ញាប័ណ្ណរួម លេខ០៩៣ ឯអ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៤
## សម្រាប់ សហគ្រាស បន្ទាយមាស អេឡិកទ្រីស៊ីធី
## ធ្វើសេវាកម្មអគ្គិសនីនៅតំបន់ទីប្រជុំជនស្រុកបន្ទាយមាស តំបន់ស្រុកកំពង់ត្រាច និងតំបន់ស្រុកអង្គរជ័យ ខេត្តកំពត និងតំបន់ស្រុកគិរីវង់ ខេត្តតាកែវ
## សម្រាប់ការពង្រីកតំបន់ចែកចាយ

**DECISION ON THE SEVENTH REVISION**
**OF THE CONSOLIDATED LICENSE DOCUMENT No. 093 LD**
**DATED AUGUST 16, 2004 FOR BANTEAY MEAS ELECTRICITY**
**FOR PROVIDING ELECTRICITY SERVICES AT BANTEAY MEAS DISTRICT AREA, KAMPONG TRACH DISTRICT AREA AND ANGKOR CHEY DISTRICT AREA, KAMPOT PROVINCE AND KIRIVONG DISTRICT AREA, TAKEO PROVINCE**
**FOR EXTENDING DISTRIBUTION AREA**

ថ្ងៃទី... ខែ... ឆ្នាំ២០០៩

..., 2009

**ព្រះរាជាណាចក្រកម្ពុជា**

**KINGDOM OF CAMBODIA**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**NATION RELIGION KING**

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ELECTRICITY AUTHORITY OF CAMBODIA**

លេខ : -០៩.អអក

# សេចក្ដីសម្រេចកែសម្រួលលើកទី៧
# លើឯកសារអាជ្ញាប័ណ្ណលេខ ០៩៣ ឯអ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤

# DECISION ON THE SEVENTH REVISION
# OF THE LICENSE DOCUMENT No. 093 LD DATED MARCH 16, 2004

## អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

-អនុវត្តតាមមាត្រា ៧, ២៩ និង ៣៤ របស់ច្បាប់ស្ដីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

- In exercise of the powers conferred by Article 7, 29 and 34 of the Electricity Law promulgated by the Royal Decree NS/RKM/0201/03, dated February 02, 2001.

-យោងឯកសារអាជ្ញាប័ណ្ណរួមលេខ០៩៣ ឯអ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤

-Refer to the Consolidated License Document No.093 LD dated March 16, 2004.

-យោងសេចក្ដីសម្រេចកែសម្រួលអាជ្ញាប័ណ្ណលើកទី៦សម្រាប់ការប្ដូរឈ្មោះពីលោកស្រី នាង គីគឹមអេង ទៅជា សហគ្រាស បន្ទាយមាស អេឡិកទ្រីស៊ីធី លេខ១៥៧សរ-០៩-អអក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩

-Refer to the decision on the sixth revision of the License Document for changing the name Mrs. Neang Kykim Eng to Banteay Meas Electricity No.029.08.EAC dated September 16, 2009.

-យោងពាក្យស្នើសុំពង្រីកតំបន់ចែកចាយរបស់លោកស្រី នាង គីគឹមអេង ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨

- In accordance with the application for extending distribution area of Mrs. Neang Kykim Eng dated August 26, 2008.

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជនដែលបានធ្វើចាប់ពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ដល់ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៩

- In accordance with the consultation with concerned parties and public, made from November 16, 2009 to December 15, 2009.

-យោងតាមការអនុម័តរបស់សម័យប្រជុំអាជ្ញាធរអគ្គិសនីកម្ពុជា លើកទី... នៅថ្ងៃទី... ខែ... ឆ្នាំ២០០៩

-In accordance with the decision of Electricity Authority of Cambodia’s Session Nº ... dated ..., 2009.

# សម្រេច

# DECIDES

| | |
|---|---|
| **ប្រការ១**<br>កែសម្រួលឯកសារអាជ្ញាប័ណ្ណ លេខ ០៩៣ ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឱ្យសហគ្រាស **បន្ទាយមាស អេឡិកទ្រីស៊ីធី** ចុះថ្ងៃទី១៦ ខែមិនា ឆ្នាំ២០០៤ សម្រាប់ធ្វើសេវាកម្មផលិត និងចែកចាយអគ្គិសនីនៅស្រុកបន្ទាយមាស និងស្រុកកំពង់ត្រាច ខេត្តកំពត ដោយអនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណពង្រីកតំបន់ចែកចាយអគ្គិសនីបន្ថែមលើតំបន់ចែកចាយអគ្គិសនី ដែលមានស្រាប់ ដូចមានបង្ហាញក្នុងផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១កែសម្រួលថ្មី ។ | **Article 1**<br>To revise the license document No. 093 LD on March 16, 2004 which was issued to **Banteay Meas Electricity** for providing electric power generation and distribution services at Banteay Meas and Kampong Trach Districts, Kampot Province to give the right to licensee to extend the existing distribution area as show in the attached map in new revised schedule 1. |
| **ប្រការ២**<br>ឧបសម្ព័ន្ធទី១ចាស់នៃឯកសារអាជ្ញាប័ណ្ណលេខ ០៩៣ ឯអ ត្រូវជំនួសដោយឧបសម្ព័ន្ធទី១ កែសម្រួលថ្មីដែលមានភ្ជាប់មកជាមួយ ។ | **Article 2**<br>The Schedule 1 of the license documents Nº 093 LD shall be replaced by new Schedule1 attached here with. |
| **ប្រការ៣**<br>សេចក្តីសម្រេច និងឧបសម្ព័ន្ធកែសម្រួលថ្មីនេះ ត្រូវចាត់ទុកជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ០៩៣ ឯអ។ | **Article 3**<br>This decision and the attached revised Schedule shall be considered as a part of the license documents Nº 093 LD. |
| **ប្រការ៤**<br>ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ០៩៣ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។ | **Article 4**<br>The other contents and conditions of the license document No. 093 LD shall remain in force. |
| **ប្រការ៥**<br>សេចក្តីសម្រេចនេះ ត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ | **Article 5**<br>The decision shall come into force from the date of signing. |
| **ប្រការ៦**<br>អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ០៩៣ ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណលេខ ០៩៣ ឯអ ដែលតម្កល់មានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។ | **Article 6**<br>The licensee shall send this decision to deposit additionally at the places, where the license document No. 093 LD has been deposited in order that the deposited license document No. 093 LD is in conformity with this decision. |

ភ្នំពេញ, ថ្ងៃទី... ខែ... ឆ្នាំ២០០៩

Phnom Penh, ...................., 2009

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF E A C

# ឧបសម្ព័ន្ធទី១
## តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី
## ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
## លើកទី... នាថ្ងៃទី... ខែ... ឆ្នាំ២០០៩

# SCHEDULE 1

## AUTHORIZED DISTRIBUTION AREAS

## AS AMMENDED IN SESSION OF EAC Nº... DATED ..., 2009

| | |
|---|---|
| ១- តំបន់អនុញ្ញាតឱ្យ សហគ្រាស បន្ទាយមាស អេឡិកទ្រីស៊ីធី ធ្វើសេវាកម្មចែកចាយ និងផ្គត់ផ្គង់អគ្គិសនី គឺ តំបន់ស្រុកបន្ទាយមាស តំបន់ស្រុកកំពង់ត្រាច និងតំបន់ស្រុកអង្គរជ័យ ខេត្តកំពត និងតំបន់ស្រុកគីរីវង់ ខេត្តតាកែវ ។ | 1. The authorized distribution Areas, where Banteay Meas Electricity has the right to provide the electricity distribution and supply services at Banteay Meas District Area, Kampong Trach District Area and Angkor Chey District Area, Kampot Province and Kirivong District Area, Takeo Province. |
| ២- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី កំណត់ដោយផែនទីកំណត់ព្រំប្រទល់ 093LD-map-Banteay Meas Electricity-Revision7-2009 ដែលភ្ជាប់មកជាមួយ ។ | 2. The authorized distribution Areas is determined by the boundary map 093LD-map-Banteay Meas Electricity-Revision7-2009 attached. |
| ៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើ សហគ្រាស បន្ទាយមាស អេឡិកទ្រីស៊ីធី មានបំណងស្នើសុំពង្រីក ឬបន្ថែមតំបន់ចែកចាយថែមទៀត ពេលនោះ សហគ្រាស បន្ទាយមាស អេឡិកទ្រីស៊ីធី ត្រូវរៀបចំឯកសារចាំបាច់នានាដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជា តាមការកំណត់របស់អាជ្ញាធរអគ្គិសនីកម្ពុជា ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជា ចេញសេចក្តីសម្រេចអនុញ្ញាតឱ្យពង្រីក ឬបន្ថែមតំបន់ចែកចាយណាមួយ ឧបសម្ព័ន្ធទី១នេះ ត្រូវធ្វើការកែសម្រួលដោយភ្ជាប់ជាមួយសេចក្តីសម្រេចឱ្យពង្រីកបន្ថែមតំបន់ចែកចាយ នោះ ។ | 3. Under this license, if Banteay Meas Electricity intends to request the extension or the additional distribution areas then Banteay Meas Electricity shall prepare all necessary documents and submit to EAC in accordance with the EAC's determination. After EAC authorized to extend or to add distribution area, this schedule 1 shall be revised and attached with that authorization. |